**១.** គណនា $-1+2-3+4-5+\dots+2020-2021$ ។

A. 1010 B. $-1011$ C. 1011 D. $-1010$ E. ចម្លើយផ្សេង

**២.** គេមានពីរចំនួនគត់វិជ្ជមាន $a$ និង $b(a>b)$ ដែលមាន $PGCD(a,b)=13$ និង $a+b=52$ ។ ចូរគណនា $\frac{a}{b}$

A. $\frac{3}{2}$ B. $\frac{4}{3}$ C. 2 D. 3 E. ចម្លើយផ្សេង

**៣.** តើមានចំនួនគត់ $n$ ចំនួនប៉ុន្មានដែលផ្ទៀងផ្ទាត់ $\frac{2}{7}<\frac{n}{13}<\frac{4}{5}$?

A. 4 B. 5 C. 6 D. 7 E. ចម្លើយផ្សេង

**៤.** នៅពេលដែលដាលីនបើកសៀវភៅគណិតវិទ្យាដាក់លើតុ នាងសង្កេតឃើញថាផលបូកលេខទំព័រសងខាងស្មើនឹង169 ។ បើនាងបន្តបើកសៀវភៅ 5សន្លឹកទៅមុខទៀត ឃើញថាចុងទំព័រទាំងសងខាងរលុបដែលធ្វើឲ្យនាងមិនអាចដឹងលេខទំព័របាន។ ចូររកលេខទំព័រដំបូងគេដែលរលុបនោះ។

A. 84 B. 94 C. 96 D. 102 E. ចម្លើយផ្សេង

**៥.** គេមាន $\overline{MOSC}=\overline{QCM}+75$ (អក្សរនីមួយៗតាងឲ្យលេខខុសៗគ្នាពី0 ដល់9)។ គណនា $M+O+S+C$ ។

A. 10 B. 15 C. 18 D. 21 E. ចម្លើយផ្សេង

**៦.** គណនា $S=\frac{1}{\left(1-\frac{1}{2}\right)\left(1-\frac{1}{3}\right)\left(1-\frac{1}{4}\right)\dots\left(1-\frac{1}{2021}\right)}$

A. $\frac{2020}{2021}$ B. $\frac{2021}{2020}$ C. $\frac{1}{2021}$ D. $\frac{1}{2020}$ E. ចម្លើយផ្សេង

**៧.** ថ្ងៃនេះជាថ្ងៃអាទិត្យ ហើយណារីមានអាយុ 2021ថ្ងៃ។ តើណារីកើតនៅថ្ងៃណាមួយនៃសប្តាហ៍?

A. ថ្ងៃច័ន្ទ B. ថ្ងៃអង្គារ៍ C. ថ្ងៃព្រហស្បត្តិ៍ D. ថ្ងៃសុក្រ E. ចម្លើយផ្សេង

**៨.** ឧបមាថាគេតម្រៀបចំនួនគត់តគ្នាជាជួរដូចដែលបានបង្ហាញខាងក្រោម

| A | B | C | D | E | F | G |
|---|---|---|---|---|---|---|
| 1 | 2 | 3 | 4 | 5 | 6 | 7 |
| 8 | 9 | 10 | 11 | 12 | 13 | 14 |
| 15 | 16 | 17 | 18 | 19 | ... | ... |

តើលេខ2021 នឹងស្ថិតនៅជួរណាមួយ?

A. ជួរ C B. ជួរ A C. ជួរ G D. ជួរ E E. ចម្លើយផ្សេង

**៩.** មុខទាំង៦នៃគូបដែលមានជ្រុង $3cm$ ត្រូវបានលាបពណ៌ក្រហម។ បន្ទាប់មកគេពុះគូបនេះជាគូបតូចៗដែលមានជ្រុង$1cm$។ តើមានគូបតូចៗចំនួនប៉ុន្មានដែលមានមុខយ៉ាងតិច២ប្រឡាក់ពណ៌ក្រហម?



A. 7 B. 20 C. 15 D. 6 E. ចម្លើយផ្សេង

**១០.** $ABCD$ ជាចតុកោណកែងដែលមានផ្ទៃក្រឡា$64cm^2$។ $E,F$ និង $G$ ជាចំនុចកណ្តាលរៀងគ្នានៃជ្រុង$AB$ , $BC$ និង$CD$ ។ គណនាផ្ទៃក្រឡានៃត្រីកោណ$EFG$ ។

A. $32cm^2$ B. $16cm^2$ C. $24cm^2$ D. $18cm^2$ E. ចម្លើយផ្សេង

**១១.** គណនា $\frac{2021}{1\times2}+\frac{2021}{2\times3}+\frac{2021}{3\times4}+\dots+\frac{2021}{2020\times2021}$។

A. $\frac{1}{2021}$ B. $\frac{1}{2020}$ C. $\frac{2020}{2021}$ D. $\frac{2021}{2020}$ E. ចម្លើយផ្សេង

**១២.** ពិសិតកំពុងសិក្សាត្រៀមប្រឡងគណិតវិទ្យាMOSC។ គាត់សម្រេចចិត្តបែងចែកម៉ោងដែលនៅសល់ប្រចាំថ្ងៃ សម្រាប់រៀនមុខវិជ្ជាពីជគណិត និងធរណីមាត្រតាមសមាមាត្រ $2:1$ ។ ប៉ុន្តែបើគាត់ចែកម៉ោងរៀនមុខវិជ្ជាទាំងពីរឲ្យស្មើគ្នាវិញនោះម៉ោងរៀនធរណីមាត្រនឹងច្រើនជាងមុន១ម៉ោង។ តើក្នុងមួយថ្ងៃពិសិតរៀនប៉ុន្មានម៉ោង?

A. ៨ម៉ោង B. ៤ម៉ោង C. ៦ម៉ោង D. ៣ម៉ោង E. ចម្លើយផ្សេង

**១៣.** គេមានរូបខាងក្រោម។ ឧបមាថា $\hat{A}=\hat{B}=\hat{C}=\hat{D}=2\hat{E}$ ចូរគណនា $\hat{A}$។



A. $15^o$ B. $20^o$ C. $30^o$ D. $45^o$ E. ចម្លើយផ្សេង

**១៤.** គេឲ្យបីចំនួន$a,b,c$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ $1001a-2002b=4004$ និង $1001c+3003b=5005$ ។ គណនាតម្លៃមធ្យមនៃ$a,b,c$ ។

A. 2 B. 3 C. 6 D. 9 E. ចម្លើយផ្សេង

**១៥.** ពេជ្រក្រឡេកមើលនាឡិកាលើជញ្ជាំង ឃើញថាដល់ម៉ោង $3:10$។ ចូររកមុំស្រួចផ្គុំដោយទ្រនិចនាទី និងទ្រនិចម៉ោង។

A. $15^o$ B. $30^o$ C. $20^o$ D. $35^o$ E. ចម្លើយផ្សេង